## ឈ្នះខ្លួនឯង ឈ្មោះថាឈ្នះរហូត *(បទពាក្យ ៧)*

*ជំនះដែលឈ្នះមិនចាញ់វិញ ឈ្នះកិលេសមិញឥតសេសសល់*
*ឈ្នះពិតជាគ្មានឧបាយកល ផ្តល់ផលឲ្យយើងចាញ់វិញបាន។*
*ធម្មតាព្រះពុទ្ធមានគោចរ អារម្មណ៍បវរអនន្តញ្ញាណ*
*គ្មានស្នាមកិលេសក្នុងសន្តាន ចង់ដោយកិលេសមិនបានឡើយ ។*
*បណ្តាញកិលេសព្រះជាម្ចាស់ បានឈ្នះរួចរស់ស្រឡះហើយ*
*រួចពីសំណាញ់យាងដល់ត្រើយ គ្មានទីណាឡើយដែលសល់ខាន ។*
*ធម្មតាព្រះពុទ្ធមានគោចរ អារម្មណ៍បវរអនន្តញ្ញាណ*
*គ្មានស្នាមកិលេសក្នុងសន្តាន នាំដោយកិលេសមិនមានជាក់ ។*
*ព្រះពុទ្ធទ្រង់នូវព្រះស្មារតី ប្រាជ្ញល្បីក្នុងឈានគ្រប់ជាន់ថ្នាក់*
*រីករាយស្ងប់ស្ងាត់ក្នុងនេក្ខម: ទេព្តាជៀងជាក់តាមបូជា ។*
*ក្របានប្រាកដភាពជាមនុស្ស ការរស់នៃសត្វក្រមហិមា*
*និងក្របានស្តាប់ព្រះធម្មា កើតជាព្រះពុទ្ធការក្រក្រៃ ។*
*មិនធ្វើនូវបាបសព្វបែបយ៉ាង ខំសាងកុសលយកនិស្ស័យ*
*ធ្វើចិត្តឲ្យល្អ រួមទាំង ៣ ទ្រឹស្តីព្រះគ្រប់អង្គសម្តែង ។*
*ខន្តី តស៊ូ ធម៌ប្រមុខ តប: សាងសុខយូរអង្វែង*
*និព្វានព្រះពុទ្ធទ្រង់សម្តែង ជាធម៌ក្រៃលែងដ៏សុខុម ។*

អ្នកបួសឬមួយសមណៈណា បៀតបៀនប្រហារសត្វតូចធំ
ឬក៏សម្លាប់ដោយចំ ៗ មិនមែនភិក្ខុ-ស្រមណ៍ទេម្ចាស់ថ្លៃ។
មិនពោលតិដៀលបៀតបៀនសត្វ ប្រតិបត្តិសង្រួមក្នុងវិន័យ
ប្រមាណក្នុងភត្តជាប្រក្រតី អាស្រ័យទីដេកអង្គុយស្ងាត់ ។
ព្យាយាមរក្សាអធិចិត្ត រំលត់កិលេសឲ្យខ្ចាយខ្ចាត់
ព្រះពុទ្ធគ្រប់អង្គទ្រង់បញ្ញត្ត ជាកិច្ចប្រតិបត្តិក្នុងសាសនា ។
ទោះជាភ្លៀងមកកើតជាប្រាក់ ជាជាក់មិនឆ្អែតដោយតណ្ហា
កាមមានរស់តិច-ច្រើនទុក្ខា អ្នកដឹងបញ្ហាគឺបណ្ឌិត ។
លោកមិនមានចិត្តនៅត្រេកអរ សូម្បីកាមនោះជាទិព្វពិត
ព្រះពុទ្ធសាវ័កលោកមានចិត្ត ត្រេកអរធម៌ពិតអស់តណ្ហា ។
មានមនុស្សជាច្រើនកាលមានភ័យ អាស្រ័យពំនឹងច្រើនប្រការ
ខ្លះយកទីភ្នំព្រៃព្រឹក្សា យកវត្តយកវ៉ា ឬចេតិយ ។
ទីពឹងទាំងនោះមិនជាក្សាន្ត ជាឧត្តមឋានតែគ្មានន័យ
មិនអាចរួចទុក្ខគ្រប់វិស័យ អាស្រ័យពំនឹងទាំងនោះឡើយ។
ជនណាបានដល់នូវព្រះពុទ្ធ ព្រះធម៌វិសុទ្ធព្រះសង្ឃហើយ
ឃើញសច្ចៈ ៤ គឺឃើញត្រើយ នេះហើយប្រាជ្ញាដ៏ប្រពៃ ។
ឃើញទុក្ខ,ឃើញការកើតនៃទុក្ខ ឃើញត្រើយទៅមុខឆ្លងផុតភ័យ
ឃើញនូវមាគ៌ានៃព្រះអរិយ៍ គឺមគ្គ ៨ ប្រសើរហោង ។

ពំនឹងទាំងនោះពិតជាក្បេម ពិតជាឧត្តមក្រៃកន្លង
ពិតជារួចចាកសព្វទុក្ខផង ពំនឹងនោះហោងមានន័យច្បាស់ ។
បុរសអាជានេយ្យក្ររកបាន មិនចេះតែកើតក្នុងឋានផ្តាស់
ផ្ទៃណាប្រាជ្ញកើតមានភ័ព្វណាស់ ជាក់ច្បាស់ត្រកូលបានសុខុម ។
កើតជាព្រះពុទ្ធសុខបវរ សម្តែងព្រះធម៌សុខឧត្តម
ព្រះសង្ឃព្រមព្រៀងសុខមនោរម្យ សង្គមបានសុខព្រោះព្រមព្រៀង ។
ការបានបូជាដល់ព្រះពុទ្ធ សាវ័កបរិសុទ្ធទាំង ៨ យ៉ាង
លះធម៌ឃឹតយូរគ្រឿងរារាំង លះខ្មាំងខ្សឹកខ្សួលសោកសៅរស់។
បូជាដល់ជនដូចបានពោល លោកបាននិព្វានគ្មានភ័យសោះ
ផលានិសង្សប្រសើរខ្ពស់ មិនអាចពិគ្រោះត្រារាប់បាន ៕

